EQUITY ENGAGEMENT & PARTNERSHIPS
LONG BEACH UNIFIED SCHOOL DISTRICT

ព្រឹត្តិបត្រព័ត៌មាន

ខែតុលា ឆ្នាំ2025 **ចេញផ្សាយ វ៉ុល 2 លេខ 2**

ចាប់ដៃគូសហការជាមួយគ្រួសារ ដើម្បីភាពជោគជ័យរបស់សិស្ស

ក្នុងខណៈដែលយើងឈានចូលខែតុលា គឺយើងមានមោទនភាព ក្នុងការឆ្លុះបញ្ចាំងលើអ្វីទាំងអស់ដែលយើងបានសម្រេចនៅក្នុងខែកញ្ញាកន្លងមកនេះ—គឺដោយមានកិច្ចសហការរបស់អ្នក។ ចាប់តាំងពីការប្រារព្ធពិធីបុណ្យ អបអរមរតកវប្បធម៌ជនជាតិអាមេរិកឡាទីន រហូតដល់ការជួយគ្រួសារជាមួយនឹងការផ្ទៀងផ្ទាត់ប្រចាំឆ្នាំ និងការស្វាគមន៍ឪពុកម្តាយជាង 300នាក់ ដែលបានចូលរួមក្នុងព្រឹត្តិការណ៍ធ្វើតេស្តពិនិត្យមេរោគរបេងដោយឥតគិតថ្លៃរបស់យើង យើងបានឃើញសហគមន៍របស់យើង បង្ហាញខ្លួនតាមមធ្យោបាយដ៏មានអត្ថន័យនៅទូទាំងមន្ទីរអប់រំ។



ដោយសម្លឹងមើលទៅមុខ សាកលវិទ្យាល័យមាតាបិតា Parent University បន្តធ្វើសិក្ខាសាលា ដែលអាចចូលរួមតាមអនឡាញ និងដោយផ្ទាល់ និងត្រូវបានបង្កើតឡើងដើម្បីជួយជ្រោមជ្រែងដល់គ្រួសារ។ ក្នុងខែនេះ យើងកំពុងរៀបចំសិក្ខាសាលាតាមអនឡាញមួយ ដែលផ្តោតលើសុខុមាលភាពសិស្ស និងមជ្ឈមណ្ឌលសុខុមាលភាពនៅតាមសាលារបស់យើង ក៏ដូចជាសិក្ខាសាលាដោយផ្ទាល់ ដើម្បីជួយឪពុកម្តាយត្រៀមលក្ខណៈក្នុងការចូលរួមប្រជុំរវាងឪពុកម្តាយនិងគ្រូបង្រៀន នាពេលខាងមុខ។ យើងក៏ចង់បញ្ជាក់ផងដែរថា វត្តមានសិក្សាទៀងទាត់គឺពិតជាសំខាន់ណាស់ — ជារៀងរាល់ថ្ងៃ ដែលសិស្សមករៀននៅសាលា គឺជួយពង្រឹងដល់ការរៀនសូត្រ ទំនុកចិត្ត និងការតភ្ជាប់ទំនាក់ទំនងរបស់សិស្សជាមួយសហគមន៍សាលារបស់ពួកគេ។



យើងខ្ញុំ សូមអញ្ជើញអ្នក ចូលរួមជាមួយយើងខ្ញុំនៅក្នុង៖ វិទ្យាស្ថានដឹកនាំគ្រួសារ (FLI) ដែលជាសិក្ខាសាលារយៈពេលពីរថ្ងៃ និងរៀបចំធ្វើនៅថ្ងៃសុក្រ និងថ្ងៃសៅរ៍ ទី24-25 ខែតុលា នេះ។ នេះជាឱកាសដ៏ល្អ ក្នុងការកសាងជំនាញដឹកនាំ និងភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារដទៃៗទៀត ដែលចូលរួមក្នុងសិក្ខាសាលានេះ។

Register Here

Dr. Lucy Salazar

ដោយធ្វើការរួមជាមួយគ្នា គឺយើងកំពុងកសាងនូវអនាគតដ៏ប្រសើររួមគ្នាមួយ៖ ក្នុង និង ជាមួយ សហគមន៍របស់យើង!

LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity

ពិធីប្រារព្ធអបអរ មរតកវប្បធម៌ជនជាតិអាមេរិកឡាទីន ខួបលើក ទី2

រូបភាពដែលបង្ហាញពីសកម្មភាពល្អៗ




















សិក្ខាលាសំរាប់មាតាបិតា
ដើម្បីរៀនសូត្រ រីកចំរើន និងពង្រឹងសិទ្ធិអំណាច រួមជាមួយគ្នា៖
នៅក្នុង និង ជាមួយ សហគមន៍

NEW

C.A.F.E.
ការចូលរួមសំរាប់សហគមន៍ និង គ្រួសារ

យើងខ្ញុំរំភើបរីករាយ សូមអញ្ជើញលោកអ្នក មកចូលរួមក្នុងសិក្ខាសាលាជាច្រើនវគ្គសំរាប់មាតាបិតា ហៅកាត់ថា C.A.F.E.។ សេចក្តីលម្អិតបន្ថែមនឹងផ្តល់ជូនក្នុងពេលឆាប់ៗនេះ!



PARENT UNIVERSITY
LONG BEACH UNIFIED SCHOOL DISTRICT



សូមចូលរួមជាមួយយើងខ្ញុំ
នៅថ្ងៃព្រហស្បតិ៍ ទី16 ខែតុលា ឆ្នាំ2025
ម៉ោង 5:30ល្ងាច នៅវិទ្យាល័យ
Browning ក្នុងសាលប្រជុំធំ

មានវគ្គសិក្ខាសាលាជាបន្តបន្ទាប់ ដែលបានរចនាបង្កើតឡើង ដើម្បីជួយ និងផ្តល់សិទ្ធិអំណាចដល់ក្រុមគ្រួសារ ឱ្យក្លាយជាដៃគូសហការដ៏ពេញលេញ នៅក្នុងការអប់រំរបស់កូនពួកគេ។
មាតាបិតា និងអ្នកមើលថែ របស់ LBUSD ត្រូវបានស្វាគមន៍ឱ្យចូលរួម។ មានផ្តល់ជូន មធ្យោបាយយានជំនិះ ការមើលថែកុមារ ការជួយធ្វើលំហាត់កិច្ចការផ្ទះ ហើយនិងសេវាបកប្រែភាសា។





វិទ្យា ស្តា នដឹកនាំ គ្រួ សា រ (FLI)

វិទ្យាស្ថានដឹកនាំគ្រួសារ ជាសិក្ខាសាលាជាច្រើនវគ្គស្តីពីការពង្រឹងសមត្ថភាព ដែលត្រូវបានបង្កើតឡើង ដើម្បីជួយអ្នកនិងគ្រួសារ ឱ្យរីកចម្រើនក្នុងការប្រាស្រ័យទំនាក់ទំនងយ៉ាងមានប្រសិទ្ធភាព ជាមួយកូនៗ សាលារៀន និងសហគមន៍របស់អ្នក។


ថ្ងៃសុក្រ និង ថ្ងៃសៅរ៍
ទី24 និង ទី25 ខែតុលា ឆ្នាំ2025
ម៉ោង 9:00ព្រឹក ដល់ 2:00រសៀល

Register Here









ក្រុមសំរាប់ការចូលរួមរបស់មាតាបិតា



ក្រុមមាតាបិតានានា

បន្ថែមពីលើកម្មវិធី CAFE ក្រុមគ្រួសារ ក៏អាចចូលរួមក្នុងក្រុមមាតាបិតានានា ដែលបង្កើតចេញពីជំនាញឯកទេស និងបទពិសោធន៍ដែលពួកគេនាំមកតាមខ្លួន ក្នុងពេលទន្ទឹមគ្នានោះដែរ ក៏ផ្តល់នូវឱកាសដ៏មានអត្ថន័យសំរាប់ការដឹកនាំ ការរីកចំរើន និងការរៀនសូត្រផងដែរ។ ក្រុមមាតាបិតាទាំងនេះ នាំមាតាបិតាឱ្យជួបជុំគ្នា ដើម្បីរៀនសូត្រអំពីគំនិតផ្តួចផ្តើមរបស់មន្ទីរជាច្រើន ចែករំលែកមតិយោបល់ និងសហការគ្នា អំពីមធ្យោបាយក្នុងការជួយជ្រោមជ្រែងដល់សិស្សទាំងអស់។ តាមរយៈការចូលរួមក្នុងក្រុមនេះ គឺមាតាបិតាមិនត្រឹមតែពង្រឹងនូវជំនាញក្នុងការដឹកនាំរបស់ពួកគេតែប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយបង្កើតនូវអនាគតរបស់សាលា និងសហគមន៍នានារបស់យើងផងដែរ។





DISTRICT COMMUNITY ADVISORY COMMITTEE

LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសហគមន៍ប្រចាំមន្ទីរអប់រំ (DCAC) គឺមានសមភាគជាតំណាងមាតាបិតាមកពីសាលា LBUSD ទាំងឡាយ ដែលឧបត្ថម្ភដោយមូលនិធិសហព័ន្ធ Title 1។ មាតាបិតា ត្រូវបានផ្តល់ឱកាសឱ្យចូលរួមពាក់ព័ន្ធ និងទទួលដំណឹងអំពីការសិក្សារបស់កូនពួកគេ។ មាតាបិតា ត្រូវបានលើកទឹកចិត្តឱ្យចែករំលែកព័ត៌មានប្រជុំ ជាមួយមាតាបិតាផ្សេងៗទៀតនៅសាលារបស់ពួកគេ។ **Next Meeting: Thursday, Oct. 30 at Teacher's Resource Center 5:30pm**



DISTRICT ENGLISH LEARNER ADVISORY COMMITTEE

LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការប្រឹក្សាសិស្សរៀនភាសាអង់គ្លេសប្រចាំមន្ទីរអប់រំ (DELAC) ជាវិធីសំរាប់ឱ្យមាតាបិតា អាចចូលរួមចំណែកក្នុងការអប់រំរបស់កូនពួកគេ នៅកម្រិតមន្ទីរអប់រំបាន។ តំណាងរបស់ DELAC មាតាបិតា ថ្នាក់ដឹកនាំមន្ទីរ និងសមាជិកសហគមន៍ ដែលចូលរួមក្នុងការប្រជុំទាំងនេះ ជារៀងរាល់ខែ។ **Next Meeting: Tuesday, Oct. 7 at Browning Multipurpose Room 9:30am**



SANKOFA PARENT VILLAGE

LONG BEACH UNIFIED SCHOOL DISTRICT

ភូមិមាតាបិតាសាំងកូហ្វា (SPV) ជាសហគមន៍មើលថែនិងជួយផ្គត់ផ្គង់សម្រាប់មាតាបិតា និងអ្នកមើលថែរបស់កុមារអាមេរិកខ្មៅ។ មន្ទីរអប់រំ LBUSD ប្តេជ្ញាផ្តោតចិត្តទុកដាក់លើតម្រូវការពិសេសរបស់សមាជិកសហគមន៍របស់យើង និងចូលរួមតាមរបៀបដែលលើកកំពស់ដល់អត្តសញ្ញាណវប្បធម៌របស់ពួកគេ។ **Next Meeting: Monday, Oct. 13 at Teacher's Resource Center 5:30pm**



EDUCATIONAL OPPORTUNITIES for NATIVE AMERICANS and NATIVE ALASKANS

LONG BEACH UNIFIED SCHOOL DISTRICT

កម្មវិធីរបស់យើង ត្រូវបានរចនាបង្កើតឡើង ដើម្បីធានាថា សិស្សជនជាតិដើមអាមេរិក (AI)/ និងជនជាតិដើមអាឡាស្កា (AN) នៅក្នុងមន្ទីរអប់រំឡុងប៊ីច មានឱកាសស្មើភាពគ្នា ក្នុងការទទួលបានការអប់រំ។ មាតាបិតា អាណាព្យាល បុគ្គលិកមន្ទីរ និងដៃគូនៅតាមសហគមន៍ ចូលរួមក្នុងការរៀបចំផែនការកម្មវិធីសិក្សា និងព្រឹត្តិការណ៍ផ្សេងៗ។ **Next Meeting: Tuesday, Oct. 28 at Browning Multipurpose Room 5:30pm**

September Highlights

VOLUNTEERS in PUBLIC SCHOOLS
LONG BEACH UNIFIED SCHOOL DISTRICT





ការធ្វើតេស្តពិនិត្យមេរោគរបេងដោយឥតគិតថ្លៃ សំរាប់អ្នកធ្វើការស្ម័គ្រចិត្ត VIPS – ពិតជាជោគជ័យដ៏ធំមែនទែន!

កម្មវិធីធ្វើតេស្តពិនិត្យមេរោគរបេងដោយឥតគិតថ្លៃ សំរាប់អ្នកធ្វើការស្ម័គ្រចិត្តនៅតាមសាលារដ្ឋ (VIPS) របស់មន្ទីរអប់រំ LBUSD កាលពីថ្ងៃអង្គារ ទី30 ខែកញ្ញា បានស្វាគមន៍ដល់បុគ្គលចំនួន 338នាក់ ដែលបានទទួលការពិនិត្យមេរោគរបេង។ យើងខ្ញុំ ពិតជាថ្លែងអំណរគុណជាអនេក ចំពោះការចំណាយពេលវេលា និងការចូលរួមរបស់គ្រួសារ ហើយនិងអ្នកស្ម័គ្រចិត្តរបស់យើង! ការចូលរួមចំណែករបស់អ្នក ជួយរក្សាសហគមន៍សាលារបស់យើង ឱ្យមានសុខភាពល្អ និងត្រៀមខ្លួនជាស្រេច ក្នុងការជួយជ្រោមជ្រែងដល់សិស្សានុសិស្ស។ យើងខ្ញុំ រង់ចាំផ្តល់ឱកាសបន្ថែមក្នុងការធ្វើតេស្តពិនិត្យរោគរបេងដោយឥតគិតថ្លៃ នាពេលអនាគតដ៏ខ្លីលើខាងមុខនេះ—សូមរង់ចាំមើលព័ត៌មានថ្មីៗ និងកាលបរិច្ឆេទក្នុងពេលឆាប់ៗនេះ។





ជំនួយគាំទ្រ ក្នុងការបញ្ចាក់ផ្ទៀងផ្ទាត់ប្រចាំឆ្នាំ

ជារៀងរាល់ឆ្នាំ ក្រុមការងារយើងខ្ញុំ រីករាយក្រៃលែង ក្នុងការជួយដល់សាលារៀន និងគ្រួសារ នៅក្នុងដំណើរការនៃការបញ្ចាក់ផ្ទៀងផ្ទាត់ប្រចាំឆ្នាំ។ កិច្ចខិតខំប្រឹងប្រែងដ៏សំខាន់នេះធានាថា ព័ត៌មានរបស់សិស្សគ្រប់រូប គឺត្រឹមត្រូវតាមបច្ចុប្បន្នកាល ហើយគ្រួសាររក្សាបាននូវការទំនាក់ទំនងគ្នា និងទទួលបាននូវការជូនដំណឹង។ យើងមានមោទនភាពក្នុងការចែករំលែកថា ពីមួយឆ្នាំទៅមួយឆ្នាំ គឺយើងបន្តជួយជ្រោមជ្រែងដល់ឪពុកម្តាយ និងអ្នកមើលថែកាន់តែច្រើនឡើង នៅទូទាំងមន្ទីរអប់រំរបស់យើង។ យើងខ្ញុំ សូមថ្លែងអំណរគុណដ៏អស់ពីដួងចិត្ត ចំពោះគ្រប់សាលា បុគ្គលិក និងគ្រួសារទាំងអស់ ដែលបានស្វាគមន៍យ៉ាងកក់ក្តៅដល់ក្រុមការងារ EEP របស់យើង ទៅកាន់បរិវេណសាលារបស់ពួកគេ និងធ្វើការយ៉ាងជិតស្និតជាមួយយើងខ្ញុំ។







ការប្រារព្ធអបអរ ទិវាអន្តរជាតិស្តីពីការបកប្រែភាសា ថ្ងៃទី30 ខែកញ្ញា



យើងខ្ញុំ បានចូលរួមជាមួយសហគមន៍សាកលោក ក្នុងការប្រារព្ធអបអរ ទិវាអន្តរជាតិស្តីពីការបកប្រែភាសា! ទិវាដ៏ពិសេសនេះ ទទួលស្គាល់នូវការងារដ៏សំខាន់នៃ <u>ការិយាល័យបកប្រែភាសាដោយផ្ទាល់មាត់ និងដោយការសរសេរ</u> របស់មន្ទីរអប់រំ LBUSD ដែលបង្កើតជាស្ពានចម្លង និងកន្លែងសំរាប់គ្រួសារទាំងឡាយ ឱ្យចូលរួមយ៉ាងពេញលេញក្នុងការអប់រំរបស់កូនពួកគាត់។

តាមរយៈការលះបង់ សមត្ថភាពវិជ្ជាជីវៈ និង ជំនាញរបស់ពួកគេ ការបកប្រែផ្ទាល់មាត់ និង ការបកប្រែឯកសាររបស់យើង ខ្ញុំ ធានាថា សំលេងរបស់គ្រួសាររាល់គ្នាគឺត្រូវគេទទួលដឹងឮ រាល់កិច្ចសន្ទនាទាំងអស់គឺមានអត្ថន័យ ហើយសិស្សគ្រប់រូបត្រូវបានផ្តល់ការជួយជ្រោមជ្រែង។ យើងខ្ញុំ ពិតជាថ្លែងអំណរគុណ ចំពោះការងារដែលអ្នកបកប្រែភាសាធ្វើជារៀងរាល់ថ្ងៃ ដើម្បីភ្ជាប់ទំនាក់ទំនងជាមួយ និង នៅក្នុងសហគមន៍សាលាដ៏ចំរុះជាតិសាសន៍នៃយើង។ យើងខ្ញុំ ក៏ចង់ស្វាគមន៍ដល់សមាជិកអ្នកបកប្រែថ្មី គឺ Chhiengmay និង Rebeca ចូលរួមក្នុងក្រុមការងារ TIU របស់យើងផងដែរ



ព្រឹត្តិការណ៍ និងឱកាសចូលរួម ក្នុងពេលឆាប់ៗខាងមុខ

ជារៀងរាល់ខែ សូមពិនិត្យមើលផ្នែកនេះ សំរាប់សិក្ខាសាលា ការជួបប្រជុំក្រុមមាតាបិតា និងព្រឹត្តិការណ៍មន្ទីរអប់រំជាច្រើន ដែលមានរៀបចំក្នុងពេលឆាប់ៗខាងមុខ។ សូមកុំរំលងឱកាសទាំងនេះណា ដើម្បីទំនាក់ទំនងគ្នា រៀនសូត្រ និងចូលរួមជាមួយសហគមន៍នៅតាមសាលារបស់យើង។



សូមចុចលើរូបភាព ដើម្បីមើលព័ត៌មានសំខាន់និងថ្មីៗ អំពីទិដ្ឋភាពហិរញ្ញវត្ថុរបស់មន្ទីរអប់រំរបស់យើង ហើយចូលមើលក្នុងទំព័រដែលរៀបរាប់ពីថវិកា។

LONG BEACH UNIFIED • SCHOOL • DISTRICT
Excellence and Equity

HUMAN RESOURCE SERVICES

Career Opportunities and Preparation

យើងខ្ញុំ ពិតជារំភើបរីករាយ ដែលអ្នកនៅទីនេះ និងត្រៀមខ្លួនជាស្រេច ដើម្បីស្វែងយល់ អំពីគេហទំព័រឱកាសអាជីពការងាររបស់ LBUSD និងការត្រៀមលក្ខណៈក្នុងការប្រើប្រព័ន្ធ Canvas។ គេហទំព័រនេះ ត្រូវបានបង្កើតឡើងសំរាប់អ្នក ហើយយើងរង់ចាំមើលនូវឱកាសរបស់អ្នកក្នុងការស្វែងយល់ និងស្គាល់ពីមន្ទីរអប់រំ ចេញពីទស្សនៈផ្សេងៗគ្នា។ គោលដៅរបស់យើង គឺទុកឱ្យអ្នកពិចារណាអំពីអ្វីដែលអាចមើលទៅ និងមានអារម្មណ៍ថាដូចជា មានការផ្លាស់ប្តូរពីការធ្វើជាសិស្សម្នាក់ ទៅជាការធ្វើជាបុគ្គលិកម្នាក់វិញ។

គេហទំព័រអាជីពការងាររបស់ LBUSD មានបង្ហាញព័ត៌មានអំពីការចុះហ្វឹកហាត់ការងារ តួនាទីការងារកំរិតជំបូងៗ សំរាប់សិស្សដែលនឹងបញ្ចប់ការសិក្សា និងឱកាសអាជីពការងារនៅក្នុងមន្ទីរអប់រំ LBUSD។ ក្នុងនោះ ក៏រួមបញ្ចូលធនធាន និងសកម្មភាពផ្សេងៗជាច្រើន ដើម្បីជួយអ្នកឱ្យប្រើប្រាស់ ក្នុងការបំពេញបែបបទដាក់ពាក្យរកការងារ និងបង្កើតជីវប្រវត្តិសង្ខេបផងដែរ។

LBUSD ចាប់ផ្តើមអនុវត្ត គោលការណ៍ច្បាប់ថ្មី ស្តីពីសុវត្ថិភាពក្នុងការប្រើប្រាស់ឧបករណ៍ និងប្រព័ន្ធផ្សព្វផ្សាយសង្គម

នៅថ្ងៃទី3 ខែកញ្ញា ឆ្នាំ2025 ក្រុមប្រឹក្សាអប់រំរបស់មន្ទីរអប់រំឡុងប៊ីច បានអនុម័តលើគោលការណ៍ច្បាប់ លេខ 5131.8៖ ការទាមទារឱ្យមានការផ្តោតយកចិត្តទុកដាក់ឡើងវិញ – ដាក់កំហិតដល់ការរំខាន និង ជួយគាំទ្រលើសុខុមាលភាព

ក្នុងការឆ្លើយតបទៅនឹងច្បាប់សភារដ្ឋកាលីហ្វ័រញ៉ា លេខ 2136 ដែលតម្រូវដល់សាលារៀនទាំងអស់ ឱយដាក់កំហិតលើការប្រើប្រាស់ទូរសព្ទ នៅក្នុងកំឡុងថ្ងៃរៀន។ សាលាដែលបានសាកល្បងអនុវត្ត គឺបានឃើញថាមានលទ្ធផលល្អហើយ ឯការអនុវត្តទូទាំងមន្ទីរអប់រំនឹងត្រូវចាប់ផ្តើមធ្វើនៅ ថ្ងៃទី26 ខែមករា ឆ្នាំ2026។ ដើម្បីជួយជ្រោមជ្រែងដល់សិស្សានុសិស្ស និងគ្រួសារបាន គឺមន្ទីរអប់រំ LBUSD កំពុងចាប់ផ្តើមយុទ្ធនាការអប់រំ អំពីហានិភ័យនៃការប្រើប្រាស់ឧបករណ៍ច្រើនហួសហេតុពេក និងវិធីសាស្ត្រក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ និងប្រព័ន្ធផ្សព្វផ្សាយសង្គមប្រកបដោយសុវត្ថិភាព។

សូមចូលរួមជាមួយយើងខ្ញុំ ក្នុងកម្មវិធីប្រជុំជាច្រើនវគ្គ ជាមួយវាគ្មិនរបស់យើង ស្តីពីការភ្ជាប់ទំនាក់ទំនងគ្នា និង ការការពារ៖

«ការស្វែងរកសុវត្ថិភាព និងតុល្យភាព ក្នុងជីវិតនៃការប្រើប្រាស់ប្រព័ន្ធឌីជីថលរបស់យើង»
ថ្ងៃច័ន្ទ ទី13 ខែតុលា ម៉ោង 6–8 ល្ងាច នៅវិទ្យាល័យ Millikan

ស្តាប់ដោយផ្ទាល់ ពីអ្នកជំនាញខាងសុវត្ថិភាពប្រព័ន្ធផ្សព្វផ្សាយសង្គមថ្នាក់ជាតិ លោក Ed Peisner និង អ្នកគ្រប់គ្រងកម្មវិធីរបស់មន្ទីរអប់រំ LBUSD លោក Chris Itson ព្រមទាំងទទួលបានធនធានព័ត៌មានក្នុងការជួយគ្រួសាររបស់អ្នក រក្សាសុវត្ថិភាពក្នុងការប្រើប្រាស់ប្រព័ន្ធអនឡាញ។ ស្វែងយល់បន្ថែមទៀត លើគេហទំព័រ lbschools.net/phonepolicy និងចូលមើលការផ្សព្វផ្សាយ (ការស្រមៃគិតឡើងវិញ អំពីការអប់រំ) Reimagin(ED) ផតខាស់/podcast ដែលផ្តោយលើសុវត្ថភាពក្នុងការប្រើប្រាស់ឧបករណ៍ និង ប្រព័ន្ធផ្សព្វផ្សាយសង្គម។

CITIZENS' OVERSIGHT COMMITTEE

RENOVATION & CONSTRUCTION
LONG BEACH UNIFIED SCHOOL DISTRICT

គណៈកម្មការត្រួតពិនិត្យរបស់ពលរដ្ឋ (COC) ដើរតួនាទីដ៏សំខាន់ក្នុងការធានានូវតម្លាភាព និងគណនេយ្យភាព នៃការប្រើប្រាស់មូលនិធិសញ្ញាបណ្ណសាលារៀននៅក្នុងមន្ទីរអប់រំឡុងប៊ីច (LBUSD) ។ រួមមានសមាជិកប្រាំពីរនាក់ ដែលត្រូវបានតែងតាំងដោយក្រុមប្រឹក្សាអប់រំរបស់ LBUSD គឺគណៈកម្មការ COC ពិនិត្យ និងរាយការណ៍ដោយយកចិត្តទុកដាក់ លើការចំណាយមូលនិធិសញ្ញាបណ្ណសាលារៀន។ សមាជិកគណៈកម្មការ COC នីមួយៗ តំណាងឱ្យផ្នែកផ្សេងគ្នានៃសហគមន៍ រួមទាំងប្រជាជនវ័យចំណាស់ ឪពុកម្តាយ អាជីវកម្ម ឬអ្នកបង់ពន្ធ។ ដោយមានការប្តេជ្ញាចិត្តក្នុងការបម្រើការងារយ៉ាងយូរបំផុតបានបីដងក្នុងអណត្តិការងាររយៈពេលពីរឆ្នាំ គឺសមាជិកគណៈកម្មការ COC នាំមកនូវទស្សនវិស័យ និងជំនាញដ៏ចម្រុះ ដល់ទំនួលខុសត្រូវត្រួតពិនិត្យរបស់ពួកគេ។

ការចូលរួមជាមួយគណៈកម្មការ COC

ក្រុមប្រឹក្សាភិបាលអប់រំរបស់ LBUSD ស្វែងរកបុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងមានចំណាប់អារម្មណ៍ ឱ្យបំរើការងារនៅក្នុងគណៈកម្មការ COC នេះ។ ប្រសិនបើអ្នក មានចំណង់ចំណូលចិត្តអំពីការចូលរួមចំណែកក្នុងការអប់រំ និងសហគមន៍ យើងខ្ញុំលើកទឹកចិត្តដល់អ្នកឱ្យដាក់ពាក្យ នៅថ្ងៃនេះតែម្តង។

តួនាទីរបស់អ្នក គឺពិតជាសំខាន់

ដោយបំរើការងារនៅក្នុងគណៈកម្មការ COC គឺអ្នកនឹងមានឱកាសធ្វើឱ្យមានផលប៉ះពាល់ដ៏មានអត្ថន័យ មកលើសាលារៀន និងសហគមន៍របស់យើង។ ការប្តេជ្ញាចិត្តរបស់អ្នក ចំពោះគណនេយ្យភាព និងការប្រើប្រាស់មូលនិធិសញ្ញាបណ្ណសាលារៀនដោយទទួលខុសត្រូវ នឹងជួយធានាថា ធនធានគឺត្រូវបានបែងចែកប្រកបដោយប្រសិទ្ធិភាព ដើម្បីជាប្រយោជន៍ដល់សិស្សានុសិស្ស និងសាលារៀនរបស់យើង។

ដាក់ពាក្យ ឥឡូវនេះតែម្តង

ចាត់វិធានការដំបូង ឆ្ពោះទៅរកការចូលរួមចំណែកក្នុងគណៈកម្មការត្រួតពិនិត្យរបស់ពលរដ្ឋ។ សូមចូលរួមជាមួយយើងខ្ញុំ ក្នុងបេសកកម្មរបស់យើង ដើម្បីគាំទ្រ និងលើកកម្ពស់ដល់ការអប់រំនៅមន្ទីរអប់រំឡុងប៊ីចនេះ។ ដាក់ពាក្យដោយចុចត្រង់កន្លែងនេះ!

យើងខ្ញុំរង់ចាំទទួលការដាក់ពាក្យរបស់អ្នក។

ខែតុលា

អាទិត្យ	ច័ន្ទ	អង្គារ	ពុធ	ព្រហស្បត្តិ៍	សុក្រ	សៅរ៍
			1 ការប្រជុំក្រុមប្រឹក្សាប់រំ ម៉ោង 5:30 ល្ងាច	2 វគ្គសិក្ខាសាលាសំរាប់ឪពុកម្តាយ នៅ អនុវិទ្យាល័យ Hamilton	3	4 Sankofa ថ្ងៃសៅរ៍ ម៉ោង 8:30 ព្រឹក
5	6	7 ការប្រជុំ DELAC Browning ម៉ោង 9:30 ព្រឹក	8 ការប្រជុំ CAC មណ្ឌលធនធានគ្រូបង្រៀន ម៉ោង 6:00 ល្ងាច	9 សកលវិទ្យាល័យមាតាបិត (តាមអនឡាញ) ម៉ោង 6:00 ល្ងាច	10	11 Sankofa ថ្ងៃសៅរ៍ ម៉ោង 8:30 ព្រឹក
12	13 មាតាបិតា Sankofa មណ្ឌលធនធានគ្រូបង្រៀន ម៉ោង 5:30 ល្ងាច	14 វគ្គសិក្ខាសាលារួមចូលរួម សំរាប់មាតាបិតា នៅសាលា Cleveland	15 ការប្រជុំក្រុមប្រឹក្សាអប់រំ ម៉ោង 5:00 ល្ងាច	16 សកលវិទ្យាល័យមាតាបិត នៅមណ្ឌលធនធានគ្រូបង្រៀន ម៉ោង 5:30 ល្ងាច	17	18 Sankofa ថ្ងៃសៅរ៍ ម៉ោង 8:30 ព្រឹក
19	20	21	22	23 ការចូលរួមរបស់មាតាបិតា វគ្គមានជាបន្តបន្ទាប់ អនុវិទ្យាល័យ Hamilton	24 វិទ្យាស្ថានដឹកនាំគ្រូសារ នៅ វិទ្យាល័យ Browning ម៉ោង 9:00 ព្រឹក	25 វិទ្យាស្ថានដឹកនាំគ្រូសារ នៅ វិទ្យាល័យ Browning ម៉ោង 9:00 ព្រឹក Sankofa Saturdays ម៉ោង 8:30 ព្រឹក
26	27	28 ការចាប់ដៃគូរសហការជាមួយមាតាបិត វិទ្យាល័យ Browning 8:30am EONA នៅវិទ្យាល័យ Browning ម៉ោង 5:30 ល្ងាច	29 ការចាប់ដៃគូរសហការជាមួយមាតាបិត វិទ្យាល័យ Browning 8:30am	30 ការប្រជុំ DCAC Tនៅមណ្ឌលធនធានគ្រូបង្រៀន ម៉ោង 5:30 ល្ងាច	31 HALLOWEEN	

Parent University



C.A.F.E.



DCAC



EONA



DELAC

